00984179

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
25 / 04 / 2014
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E306

សាធារណៈ / Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់

១. មុនពេលចាប់ផ្តើមសវនាការសំណុំរឿង០០២ ភាគីបានដាក់អញ្ញត្រកម្មអនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង។ នៅពេលនោះ អង្គជំនុំជម្រះបានដោះស្រាយទៅលើអញ្ញត្រកម្មទាំងឡាយណាដែលខ្លួនយល់ឃើញថាមានភាពពាក់ព័ន្ធ និងចាំបាច់ដែលត្រូវសម្រេចជាមុន មុនពេលដំណើរការនីតិវិធីដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ (ឧទាហរណ៍ សូមមើលឯកសារE51/14, E116, E100/6, E122, E95/8, E51/15)។ នៅពេលនោះដែរ អង្គជំនុំ-ជម្រះក៏បានបញ្ជាក់ថា អញ្ញត្រកម្មមួយចំនួនទៀតនឹងលើកទៅដោះស្រាយនៅដំណាក់កាលជំនុំជម្រះក្រោយៗទៀត (សូមមើលឯកសារ E124 លេខជើងទំព័រ ៧ ឯកសារ E284 លេខជើងទំព័រ ២១២, ២៦៨, ២៧១, ២៧៣-២៧៥)។ ទាក់ទិននឹងបញ្ហានេះ អង្គជំនុំជម្រះផ្តល់នូវការបញ្ជាក់ដូចខាងក្រោមនេះ និងស្វែងរកព័ត៌មានបន្ថែមពីភាគី។

២. ជាបឋម អង្គជំនុំជម្រះយល់ឃើញថា បញ្ហានានាមួយចំនួនដែលបានលើកឡើងដោយភាគីថាជាអញ្ញត្រកម្មនោះគឺមិនពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ដូចដែលមានចែងក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុងទេ។ ចំណោទបញ្ហាដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង (ឯកសារ E51/4 កថាខណ្ឌ ២៧(ង) និងឯកសារ D427/1/6 កថាខណ្ឌ ២០៥

២០៧ សូមមើលឯកសារ E188 កថាខណ្ឌ ៣៤៧,៣៥១(សំណុំរឿង ០០១)) ត្រូវបានចាត់ទុកថាជាសំណើសុំប្តូរការកំណត់បទចោទអនុលោមតាមវិធាន៩៨(២) នៃវិធានផ្ទៃក្នុង និងពាក់ព័ន្ធទៅនឹងការកំណត់ថាតើចារីនៃបទល្មើសដែលត្រូវបានចោទប្រកាន់ មានចេតនាឧក្រិដ្ឋដែរ ឬទេ អនុលោមតាមនិយមន័យនៃឧក្រិដ្ឋកម្មនេះ។ ហេតុដូច្នេះ ចំណុចនេះនឹងមានបញ្ជាក់នៅក្នុងសាលក្រម។ ភាគីក៏បានចោទជាសំណួរថាតើអង្គហេតុនៅក្នុងដីកាដំណោះស្រាយបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់គ្រាប់គ្រាន់ដែរឬទេ ក្នុងការបង្កើតបានជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ឯកសារE58 កថាខណ្ឌ៧-១០)។ ដើម្បីដោះស្រាយការប្រឈមនេះ អង្គជំនុំជម្រះត្រូវពិនិត្យលើអង្គហេតុ និងភស្តុតាងមុនពេលអនុវត្តទៅតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់។ ហេតុនេះ អង្គជំនុំជម្រះរក្សាសិទ្ធិមិនទាន់សម្រេចលើបញ្ហានេះរហូតដល់ដំណាក់កាលចេញសាលក្រម។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងអង្គបុរេជំនុំជម្រះ (ឯកសារ D427/3/15 កថាខណ្ឌ ១៦៦) ដែលថាមានការប្រឈមផ្នែកអង្គច្បាប់ និងអង្គហេតុចំពោះការចោទប្រកាន់អំពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ នៅក្នុងក្របខណ្ឌនៃការរៀបការដោយបង្ខំ (ឯកសារ E44 កថាខណ្ឌ ២៥-៣០)។ អង្គជំនុំជម្រះចាត់ទុកថាវាមិនទាន់ដល់វេលាសមស្របក្នុងការដោះស្រាយបញ្ហាទាំងនេះ មុនពេលចេញសាលក្រមក្នុងសំណុំរឿង ០០២/០២ នោះទេ។

៣. ជាងនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានច្បាប់សម្រាប់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបន្ថែមទៅក្នុងដីកាដំណោះស្រាយនូវការចោទប្រកាន់ចំពោះការរំលោភសេពសន្ថវៈ (ក្រៅក្របខណ្ឌនៃការរៀបការដោយបង្ខំ) ដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខនានាឡើយ (ឯកសារ E99/1 កថាខណ្ឌ ៣២-៤១, ៤៣, ៤៥) ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ការរំលោភសេពសន្ថវៈពុំកើតមានឡើងនៅមន្ទីរសន្តិសុខទេ ហើយបទល្មើសទាំងនេះមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីចោទប្រកាន់ចំពោះជនជាប់ចោទបានដែរ ដោយហេតុថាពុំមានភស្តុតាងគាំទ្រដែលថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យប្រើប្រាស់គោលនយោបាយការរំលោភសេពសន្ថវៈនៅក្នុងមន្ទីរសន្តិសុខឡើយ (ឯកសារD427 កថាខណ្ឌ ១៤២៦-១៤២៨)។ ទោះបីជាអង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាដំណោះស្រាយបានក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះ *មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ* (វិធាន៩៨(២)) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចបញ្ចូលអង្គហេតុ ឬបទចោទថ្មីទៅក្នុងដីកាដំណោះស្រាយ ដែលអង្គហេតុ ឬបទចោទនោះត្រូវបាន

00984181

E306

បដិសេធដោយសហចៅក្រមស៊ើបអង្កេត ហើយដែលអង្គបុរេជំនុំជម្រះពុំមានជំហរផ្សេងពីសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះ។

៤. ចំពោះបញ្ហាដោយឡែកមួយទៀត អង្គជំនុំជម្រះកត់សម្គាល់ថា អញ្ញត្រកម្មទាក់ទិននឹងមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់កំណត់និយមន័យនៃការធ្វើទារុណកម្ម (ឯកសារ E83 កថាខណ្ឌ៩) ហើយនឹងសំណើសុំកំណត់បទល្មើសរំលោភសេពសន្ថវៈទៅជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបដិសេធរួចហើយ (ឯកសារ F28 កថាខណ្ឌ ១៩០, ១៨៣, ២០៤, ២១៣)។

៥. ដោយពិចារណាទៅលើសំអាងហេតុខាងលើ អង្គជំនុំជម្រះយល់ឃើញថាមានអញ្ញត្រកម្មនៅសេសសល់ចំនួនពីរ ដែលអង្គជំនុំជម្រះគួរដោះស្រាយនៅពេលនេះ ពោលគឺ៖ អាជ្ញាយុកាលបទល្មើសនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ (ឯកសារ E43; E83 កថាខណ្ឌ ៦) និងយុត្តាធិការទៅលើការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ឯកសារ E58 កថាខណ្ឌ ១១)។ ទោះបីជាពេលវេលាកំណត់នៃការដាក់អញ្ញត្រកម្មបានកន្លងផុតទៅហើយក្ដី (ឯកសារ E51) ប៉ុន្តែអង្គជំនុំជម្រះអាចទទួលបានប្រយោជន៍នៃព័ត៌មានពីភាគីទាក់ទិននឹងបញ្ហាទាំងនេះ ដោយហេតុថា បញ្ហាទាំងនេះត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្ដី អៀង សារី មុនផុតកំណត់ពេលវេលាសម្រាប់លើកឡើងអំពីអញ្ញត្រកម្ម ។ ជាបឋមភាគីត្រូវបញ្ជាក់ប្រាប់អង្គជំនុំជម្រះថា តើខ្លួនយល់ស្របទៅនឹងអញ្ញត្រកម្មដែលលើកឡើងដោយក្រុមមេធាវីការពារក្ដី អៀង សារី ដែរ ឬទេ។ ប្រសិនបើយល់ស្រប ភាគីត្រូវបញ្ជាក់នូវជំហរនានារបស់ខ្លួនទៅលើបញ្ហានេះ ក្នុងសារណារួមមួយដែលមិនឲ្យលើសពី ១៥ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ៣០ ទំព័រជាភាសាខ្មែរ។ ពេលវេលាកំណត់ដាក់សារណានេះគឺត្រឹមថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤។

៦. អញ្ញត្រកម្មផ្សេងទៀតដែលនៅសេសសល់នឹងត្រូវសម្រេចនៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះនឹងមិនទទួលនូវសារណាទៅលើអញ្ញត្រកម្មណាមួយផ្សេងទៀតឡើយ ហើយភាគីក៏ពុំអាចលើកពីអញ្ញត្រកម្មថ្មីបន្ថែមទៀតដែរនៅក្នុងពេលនេះ។